# គណបក្សកាន់អំណាចនិងគណបក្សប្រឆាំងអាចនឹងជួបចរចាក្នុងពេលខាងមុខ



ដោយ ថា កិត្យា RFA 2016-06-09

គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ អាចនឹងជួបចរចាគ្នាពេលខាងមុខនេះ ដើម្បីលើកកម្ពស់វប្បធម៌សន្ទនា។ ជំហរងាករកវប្បធម៌សន្ទនាឡើងវិញនៅពេលនេះ គឺបន្ទាប់ពីអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីមូន (Ban Ki-Moon) សម្ដែងការព្រួយបារម្ភពីស្ថានភាពនយោបាយកម្ពុជា បច្ចុប្បន្ន ហើយជំរុញឲ្យគណបក្សទាំងពីរចរចាដោះស្រាយគ្នាជាបន្ទាន់។ ការព្រួយបារម្ភរបស់លោក បាន គីមូន នោះ គឺពាក់ព័ន្ធនឹងការចាប់ខ្លួនអ្នកនយោបាយ សកម្មជនសិទ្ធិមនុស្ស និងការបំភិតបំភ័យប្រព័ន្ធផ្សព្វផ្សាយ និងប្រជាពលរដ្ឋ។

វប្បធម៌សន្ទនាអាចនឹងរស់រវើកឡើងវិញ បន្ទាប់ពីគណបក្សប្រជាជនកម្ពុជា ដែលធ្លាប់តែបែរខ្នងដាក់បក្សប្រឆាំងមួយរយៈនោះ ពេលនេះបានបង្ហាញជំហរទន់ភ្លន់វិញថា ក្រុមការងារគណបក្សទាំងពីរអាចនឹងវិលចូលតុចរចាក្នុងពេលខាងមុខនេះ។

អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន ថ្លែងថា ក្រុមការងារចរចាដែលអាចជួបគ្នានៅពេលខាងមុខ មិនមែនជាការជួបគ្នារវាងថ្នាក់ដឹកនាំមតិភាគច្រើន ដឹកនាំដោយលោក ស ខេង និងថ្នាក់ដឹកនាំនៃមតិភាគតិច ដឹកនាំដោយ លោក កឹម សុខា នោះទេ។ លោកថា ជំនួបលើកនេះ គឺជាជំនួបរវាងក្រុមការងាររបស់បក្សទាំងពីរ ដែលមានសមាសភាពម្ខាង ៥រូប ខាងគណបក្សប្រជាជនកម្ពុជា ដឹកនាំដោយលោក ព្រុំ សុខា រដ្ឋ

លេខាធិការក្រសួងមហាផ្ទៃ ឯខាងគណបក្សសង្គ្រោះជាតិ ដឹកនាំដោយលោក ប៉ុល ហំម ប្រធានគណៈកម្មាធិការនាយកគណបក្សសង្គ្រោះជាតិ៖ «»។

ការបង្ហាញជំហរវិជ្ជមានក្នុងការចរចានៅពេលនេះ កើតឡើងបន្ទាប់ពីអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីមូន បានសន្ទនាតាមទូរស័ព្ទជាមួយលោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា កាលពីល្ងាចថ្ងៃទី៧ ខែមិថុនា។

ក្នុងជំនួបសន្ទនានោះ លោក បាន គីមូន បានបង្ហាញក្តីព្រួយបារម្ភជុំវិញសេចក្តីរាយការណ៍អំពីការបំភិតបំភ័យ ការរំលោភបំពាន និងការចាប់ខ្លួនមន្ត្រីអង្គការសង្គមស៊ីវិល សមាជិក គ.ជ.ប និងសមាជិកគណបក្សប្រឆាំង ព្រមទាំងបំភិតបំភ័យដល់ប្រព័ន្ធផ្សព្វផ្សាយ ដែលកំពុងរីករាលដាលនៅកម្ពុជា។

អគ្គលេខាធិការអង្គការសហប្រជាជាតិ សង្ឃឹមថា រដ្ឋាភិបាលកម្ពុជា នឹងធានានូវការគោរពសិទ្ធិមនុស្សពេញលេញ រួមបញ្ចូលទាំងសេរីភាពនៃការបញ្ចេញមតិ សេរីភាពខាងសមាគម និងសេរីភាពនៃការប្រមូលផ្តុំ។ លោក បាន គីមូន អំពាវនាវដល់គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ឲ្យបន្តវប្បធម៌សន្ទនាតទៅទៀត។

ទន្ទឹមគ្នានេះ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិជាង ៩០ស្ថាប័ន ក៏បានរួមគ្នាចេញសេចក្តីអំពាវនាវដល់រដ្ឋាភិបាល ឲ្យបញ្ឈប់ប្រើប្រាស់ប្រព័ន្ធតុលាការ ចាប់ខ្លួន និងឃាំឃាំងចំពោះពលរដ្ឋដែលគ្រាន់តែសម្តែងមតិ និងប្រើប្រាស់សិទ្ធិស្របច្បាប់របស់ពួកគេ ដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិផ្សេងៗដែលកម្ពុជា ទទួលស្គាល់ជាច្បាប់កម្ពុជា។

អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា ស្វាគមន៍ការចាប់អារម្មណ៍របស់លោក បាន គីមូន លើកម្ពុជា តែលោកសោកស្តាយដែលលោក បាន គីមូន ហាក់ក្តាប់មិនបានពីតថភាពសង្គមកម្ពុជា បច្ចុប្បន្ន ដែលនាំឲ្យមានការយល់ច្រឡំថា គណបក្សកាន់អំណាចគាបសង្កត់លើបក្សប្រឆាំង៖ «»។

ទាក់ទងបញ្ហានេះ វិទ្យុអាស៊ីសេរី មិនទាន់អាចសុំការឆ្លើយតបពីគណបក្សសង្គ្រោះជាតិ បានទេនៅថ្ងៃទី៨ ខែមិថុនា។ តែមន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ លោក អេង ឆៃអ៊ាង បានប្រាប់សារព័ត៌មានថ្មីៗថា លោកគាំទ្រចំពោះក្តីកង្វល់របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅពេលនេះ។ លោកថា ក្តីកង្វល់របស់លោក បាន គីមូន បង្ហាញឲ្យឃើញថា វិបត្តិនយោបាយនៅកម្ពុជា មិនមែនតែប្រជាពលរដ្ឋខ្មែរនោះទេ។ លោក អេង ឆៃអ៊ាង ឲ្យដឹងដែរថា លោកមិនទាន់បានព័ត៌មានច្បាស់នៃការជួបចរចាគ្នារវាងក្រុមការងារបក្សទាំងពីរឡើយ ហើយលោកឲ្យដឹងទៀតថា បច្ចុប្បន្ន កម្ពុជា មានវិបត្តិនយោបាយ ដូច្នេះត្រូវតែចរចាគ្នាពីវិបត្តិនេះ។

កាលពីថ្ងៃទី១៩ ខែឧសភា សមាជិកសភាមកពីគណបក្សសង្គ្រោះជាតិ ទាំង ៥៥រូប តំណាងឲ្យអ្នកបោះឆ្នោត ៤៥% បានចុះហត្ថលេខារួមគ្នាលើលិខិតផ្ញើជូនលោក បាន គីមូន ឲ្យបើកកិច្ចប្រជុំបន្ទាន់ជាមួយប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីដោះស្រាយបញ្ហានៅកម្ពុជា ពិសេសបញ្ហារំលោភបំពានសិទ្ធិមនុស្សប្រព្រឹត្តដោយគណបក្សកាន់អំណាច។ លិខិតបន្តទៀតថា ស្ថាប័នសំខាន់ទាំងបីរួមមាន អង្គការនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ត្រូវបានគណបក្សកាន់អំណាចយកទៅប្រើប្រាស់ដើម្បីរំលាយគណបក្សប្រឆាំង។

សាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយ លោក សុ ចន្ថា មានប្រសាសន៍ថា ការព្រួយបារម្ភរបស់អង្គការសហ

ប្រជាជាតិ គឺមានឥទ្ធិពលខ្លាំងមកលើកម្ពុជា ព្រោះថា កម្ពុជា គឺជាសមាជិកនៃអង្គការសហប្រជាជាតិ ដែលត្រូវតែគោរពអ្វីដែលជាបទដ្ឋានច្បាប់ និងគោលការណ៍ប្រជាធិបតេយ្យដែលអង្គការសហប្រជាជាតិ បានចែងជាសកល៖ «»។

រីឯអ្នកស្រាវជ្រាវផ្នែកទំនាក់ទំនងអន្តរជាតិ និងអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ លោក ឆាំ ប៊ុនថេត មានប្រសាសន៍ថា ការអំពាវនាវរបស់អង្គការសហប្រជាជាតិ និងសង្គមស៊ីវិល ហាក់មិនមានឥទ្ធិពលខ្លាំងដើម្បីជំរុញរដ្ឋាភិបាល ឬបក្សកាន់អំណាចឲ្យផ្លាស់ប្ដូរឥរិយាបថរបស់ខ្លួននោះឡើយ៖ «»។

មួយរយៈចុងក្រោយនេះ ស្ថានភាពនយោបាយកម្ពុជា ចាប់ផ្ដើមអូអាប់បន្ទាប់ពីអ្នកនយោបាយគណបក្សប្រឆាំងជាច្រើនរូប និងសកម្មជនសិទ្ធិមនុស្ស ព្រមទាំងសមាជិក គ.ជ.ប ម្នាក់ កំពុងជាប់ឃុំ ខណៈអ្នកនយោបាយបក្សប្រឆាំងមួយចំនួនទៀត កំពុងជាប់បណ្ដឹងនៅតុលាការ ដែលសំណុំរឿងទាំងអស់នេះ ត្រូវអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិមួយចំនួនមើលឃើញថា ជាសំណុំរឿងនយោបាយ៕